**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ....៣១១....ស.ភ.រ

ថ្ងៃអង្គារ ៩ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី..២០.. ខែសីហា ឆ្នាំ២០១៨

# សេចក្តីអំពាវនាវ

សាលាភូមិន្ទរដ្ឋបាល សូមជម្រាបជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជ្រាបថា សាលាភូមិន្ទរដ្ឋបាលបាននិងកំពុងរៀបចំកសាងឧទ្យានបៃតងនិងកែលម្អស្រះទឹកក្នុងបរិវេណសាលា ដើម្បីប្រែក្លាយបរិស្ថានសាលាកាន់តែមនោរម្យសម្រាប់ការសិក្សានិងការបំពេញការងារ។ សាលាសូមអំពាវនាវនូវសមានចិត្តចូលរួមវិភាគទានរបស់សប្បុរសជន ក្នុងការរៀបចំឧទ្យានបៃតងនិងការកែលម្អស្រះទឹក ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. ការរៀបចំឧទ្យាន

- ការដាំដើមឈើធំ ចំនួន ១៧ ដើម បន្ថែមលើដើមឈើធំដែលមានស្រាប់
- រៀបចំរូបសំណាកអំពីថ្មភក់តំណាងសិស្ស កម្មសិក្សាការី អង្គុយអានសៀវភៅក្នុងឧទ្យាន
- រៀបចំការចារឹកសំដីមាសរបស់អ្នកប្រាជ្ញ និង ថ្នាក់ដឹកនាំខ្មែរលើផ្ទាំងថ្មភក់ដំកល់ក្នុងឧទ្យាន
- រៀបចំផ្លូវដើរ កម្រាលស្មៅបៃតង ការតុបតែងផ្កាលម្អតាមដើមឈើ និងក្នុងឧទ្យាន
- រៀបចំប្រព័ន្ធភ្លើងបំភ្លឺលម្អឧទ្យាន កៅអីអង្គុយ និងការរៀបចំលម្អផ្សេងៗ។

២. ការកែលម្អស្រះទឹក

- របងព័ទ្ធជុំវិញមានប្រវែងប្រមាណ ៥៣ ម៉ែត្រ
- របងរៀបចំជា ២ (ពីរ)ថ្នាក់ ដែលអាចអង្គុយនិងដើរកាត់ជុំវិញស្រះ ដោយមានរៀបចំគ្រឹះបាត និងបិទថ្មបាយក្រៀមជុំវិញ
- បង្គោលរបងព័ទ្ធជុំវិញ ចំនួន២៥ដើម ធ្វើអំពីថ្មភក់ទំហំ ០.២ម៉ែត្របួនជ្រុង ឆ្លាក់តាមរចនាបទខ្មែរបុរាណ កម្ពស់ ១ (មួយ) ម៉ែត្រពីបាត ឆ្លាក់អក្សរតំណាងរាជធានី ខេត្ត ទាំង២៥ និងមានខ្សែពួរភ្ជាប់ពីបង្គោលមួយទៅបង្គោលមួយ
- រៀបចំកូនភ្នំថ្ម បង្ហូរទឹកជាប់មាត់ស្រះ ប្រព័ន្ធបាញ់ទឹកក្នុងស្រះ ប្រព័ន្ធភ្លើងបំភ្លឺជុំវិញស្រះ។

**ក្នុងករណី សប្បុរសជនចូលរួមថវិកាសម្រាប់ការកសាងឧទ្យានបៃតងនិងកែលម្អស្រះទឹក ចាប់ពី ៤ លានរៀល (ឬ ១ពាន់ដុល្លាអាមេរិក) សាលានឹងចារឹកនាមរបស់សប្បុរសជនជាប់នឹងដើមឈើ (មានត្រឹម ១៧ដើម) ឬ ឆ្លាក់លើថ្មភក់ដំកល់ទុកក្នុងឧទ្យាន។** ទោះជាយ៉ាងណា សាលាស្វាគមន៍និងថ្លែងអំណរគុណចំពោះការរួមចំណែកក្នុងកម្រិតណាមួយផ្សេងទៀតរបស់សប្បុរសជនក្នុងការរៀបចំឧទ្យានបៃតង និងការកែលម្អស្រះទឹក ផងដែរ។

សាលាភូមិន្ទរដ្ឋបាល សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅទុកជាមុនចំពោះការរួមចំណែករបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ក្នុងការអភិវឌ្ឍសាលាភូមិន្ទរដ្ឋបាល។

**សាលាភូមិន្ទរដ្ឋបាល**

សូមផ្តល់ព័ត៌មានអំពីការចូលរួមវិភាគទាន តាមរយៈ៖

-លោក សួន ជាថា ០១៦ ៥៩៤ ៣៣៦

-លោក យ៉ុន ថាយុទ្ធ ០៩៩ ៨០៨ ៨៩៦

-កញ្ញា មាស សុភី ០១៥ ៨៣៨ ៤៨៤





Project:

Project
Design Sculpture at
Royal Administration
school

11 August 2018

Architect:
Thy Tarasy
#180 St 109, Mittaphap
7Makara, Phnom Penh
Tel: 086961006
tarasythy@gmail.com

Title:
3D View

Paper sheet:
A05